# <u>បុព្វកថា</u>

សៀវភៅនេះ ខ្ញុំសរសេរឡើង ដើម្បី រំលិកឡើងវិញ នូវទ្រឹស្តី ឬ វត្ថុ  ដែលយើងធ្លាប់
បានឃើញ បានប្រើរួចមកហើយ តែពុំទាន់បានឃើញការបង្ហាញ ឬ បានស្គាល់នូវ ដើម
កំណើតនៃទ្រឹស្តីទាំងនោះ ។ ឧបមាដូចជាចំនួនគត់ ដែលយើងប្រើសព្វថ្ងៃនេះ តើកើត
ឡើងដោយរបៀបណា ?  ម្យ៉ាងទៀតទោះបើជាមានទ្រឹស្តី ដែលយើងធ្លាប់ស្គាល់
ហើយក៏ដោយ  ក៏របៀបបង្ហាញនូវទ្រឹស្តីនោះ អាចជាទុកជាចម្លើយគំរូ សម្រាប់យើងទៅ
ថ្ងៃក្រោយ ។ ហើយសញ្ញាញខ្លះ ក៏អាចទុកជាស្ពានសម្រាប់ឆ្លងទៅរកសញ្ញាណ
ថ្មីទៀតនៅមហាវិទ្យាល័យ  ចំពោះនិស្សិតដែលចង់បន្តខាង សាខាគណិតសាស្ត្រនេះ។
អត្ថបទទាំងឡាយដែលខ្ញុំយកមកជូននៅពេលនេះ ខ្ញុំបានដកស្រង់ពីឯកសារផ្សេងៗ
សរសេរដោយ លោកសាស្ត្រាចារ្យបរទេសដ៏ល្បីៗ ។ ខ្ញុំអត់មានបង្កើតនូវទ្រឹស្តីអ្វីមួយថ្មីទេ។
ខ្ញុំគ្រាន់តែយកមក សសេរ និង ពន្យល់តាម របៀបខ្ញុំដែលមានបំណងចង់ឲ្យលោកអ្នក
អានងាយយល់ ហើយជាភាសាខ្មែរថែមទៀត ។ ពោលគឺទ្រឹស្តីនៅតែដដែលដូចដើម
តែរបៀបពន្យល់អាចថែមថយ ហើយខុសពី ឯកសារដើម ។ ខ្ញុំមិនមែនជាអ្នកចេះដឹងជ្រៅ
ជ្រះខាងគណិតសាស្ត្រទេ  ខ្ញុំគ្រាន់តែមានការពិសោធន៍ខ្លះខាងមុខវិជ្ជានេះ។
ដោយឯកសារ ទាំងនោះជាភាសាបារាំង   ដូច្នេះចំពោះពាក្យបច្ចេកទេស ខ្លះដែលខ្ញុំ
ពុំហ៊ានបកប្រែ  នោះខ្ញុំសូមទុកជាភាសាបារាំង សម្រាប់ក្រសួងសិក្សាធិការជាតិ បកនៅ
ពេលក្រោយ ។

ខ្ញុំសង្ឃឹមថា សៀវភៅនេះ អាចជួយ លោកអ្នក បានខ្លះ ចំពោះការសិក្សានូវមុខវិជ្ជានេះ ។

Champs-sur-Marne, le  15/05/2020.

អាន ត្យាគីម ។